# សេវាកម្មសម្រាប់ជនរងគ្រោះនៃបទឧក្រិដ្ឋកម្មក្នុងរដ្ឋវិចថូរៀ - ខ្មែរ

បណ្ដាញទូរស័ព្ទជំនួយជនរងគ្រោះនៃបទឧក្រិដ្ឋកម្មរបស់រដ្ឋាភិបាលរដ្ឋវិចថូរៀ ផ្ដល់ជូនព័ត៌មាន ដំបូន្មាន និងការគាំទ្រ ដោយឥតគិតថ្លៃសម្រាប់អ្នក និងក្រុមគ្រួសាររបស់អ្នក។

**បណ្ដាញទូរស័ព្ទជំនួយជនរងគ្រោះនៃបទឧក្រិដ្ឋកម្ម**
បើក៖ ម៉ោង 8 ព្រឹក -11 យប់ 7 ថ្ងៃក្នុងមួយសប្ដាហ៍
ទូរស័ព្ទ៖ 1800 819 817
ទូរសារ៖ 0427 767 891
អ៊ីម៉ែល៖ vsa@justice.vic.gov.au

**ទូរស័ព្ទ ផ្ញើសារ ឬអ៊ីម៉ែលទៅបណ្ដាញទូរស័ព្ទជំនួយដើម្បី៖**

- ស្វែងរកវិធីរាយការណ៍អំពីបទឧក្រិដ្ឋកម្មទៅប៉ូលិស
- ស្វែងរកសេវាកម្មផ្សេងទៀតដែលអាចជួយអ្នក
- ទទួលបានព័ត៌មានអំពីរបៀបដែលប្រព័ន្ធយុត្តិធម៌រដ្ឋវិចថូរៀដំណើរការ
- ទទួលបានការគាំទ្រ ប្រសិនបើអ្នកត្រូវការធ្វើជាសាក្សីនៅតុលាការ
- ទទួលបានជំនួយក្នុងការដាក់ពាក្យសុំសំណង និងជំនួយហិរញ្ញវត្ថុប្រសិនបើអ្នកមានសិទ្ធិទទួល
- ស្វែងយល់ពីអ្វីដែលអ្នកអាចធ្វើបានដើម្បីការពារអ្នក និងក្រុមគ្រួសាររបស់អ្នកឱ្យមានសុវត្ថិភាព។

**ប្រសិនបើអ្នកស្ថិតក្នុងសភាពគ្រោះថ្នាក់ឥឡូវនេះ សូមទូរស័ព្ទទៅប៉ូលិសលេខសូន្យបីដង (000)។ អ្នកក៏អាចទៅប៉ុស្តិ៍ប៉ូលិសបានដែរ។**

**យើងជួយមនុស្សក្នុងស្ថានភាពខុសៗគ្នាជាច្រើន**
រៀងរាល់ឆ្នាំ យើងជួយមនុស្សរាប់ពាន់នាក់ដែលមានអាយុខុសគ្នា ភេទ និងសាវតាដែលជាជនរងគ្រោះដោយ បទឧក្រិដ្ឋកម្ម។

**យើងអាចជួយបាន ទោះបីជាអ្នកមិនចង់រាយការណ៍ពីបទឧក្រិដ្ឋកម្មទៅប៉ូលិសក៏ដោយ**
មានហេតុផលល្អៗដើម្បីប្រាប់ប៉ូលិសអំពីឧក្រិដ្ឋ។ ពួកគេនឹងទទួលយករបាយការណ៍របស់អ្នកយ៉ាងហ្មត់ចត់បំផុត ហើយព្យាយាមស្វែងរកអ្នកដែលបានប្រព្រឹត្តបទឧក្រិដ្ឋ។ ពួកគេក៏អាចការពារអ្នកបានដែរ។

ប្រសិនបើអ្នកមិនទាន់បានត្រៀមរួចរាល់ដើម្បីធ្វើរបាយការណ៍ ឬព្រួយបារម្ភអំពីការនិយាយទៅកាន់ប៉ូលិស បណ្ដាញទូរស័ព្ទជំនួយនឹង៖

- និយាយជាមួយអ្នក ដោយមានការយល់ដឹងពីស្ថានភាពរបស់អ្នក
- ស្វែងរកសេវាកម្មដែលអាចជួយអ្នក ទោះបីជាអ្នកមិនចង់រាយការណ៍អំពីបទឧក្រិដ្ឋកម្មក៏ដោយ
- ជួយអ្នកនិយាយជាមួយប៉ូលិស ប្រសិនបើអ្នកចង់។

**អ្នកអាចប្រើអ្នកបកប្រែផ្ទាល់មាត់**
បណ្ដាញទូរស័ព្ទជំនួយ នឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ជូនអ្នកឥតគិតថ្លៃ ប្រសិនបើអ្នកត្រូវការ។ អ្នកក៏អាចស្នើសុំឱ្យនរណាម្នាក់ផ្សេងទៀត ទូរស័ព្ទមកបណ្ដាញទូរស័ព្ទជំនួយដើម្បីទទួលបានអ្នកបកប្រែផ្ទាល់មាត់សម្រាប់អ្នកបានដែរ។

ដើម្បីទទួលបានអ្នកបកប្រែផ្ទាល់មាត់

1. ទូរស័ព្ទទៅបណ្ដាញទូរស័ព្ទជំនួយលេខ 1800 819 817
2. ប្រាប់ពួកគេនូវឈ្មោះរបស់អ្នក លេខទូរស័ព្ទ និងភាសា
3. អ្នកបកប្រែផ្ទាល់មាត់នឹងទូរស័ព្ទមកអ្នកវិញ។

នៅពេលអ្នកបកប្រែទូរស័ព្ទមក វាអាចបង្ហាញជា’private number’, 'blocked' ឬ 'no caller id' នៅលើទូរស័ព្ទដៃរបស់អ្នក។



VICTORIA State Government | Justice and Community Safety